**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

លេខ ....០៥....សាសន

ថ្ងៃទី 24 ខែ 3 ឆ្នាំ 2006

# សេចក្តីសំរេច

## ស្តីពី

## ការកំណត់បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់

☆☆☆☆☆☆

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផ្អែកតាមអនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- ផ្អែកតាមអនុក្រឹត្យលេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងប្រកាសលេខ ៦៤ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង និងតួនាទីភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- យោងលិខិតលេខ ៧៧៩ ដនស/អដន/០៤ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីកំណែទំរង់សេវាត្រួតពិនិត្យពាក្យសុំ និងផ្តល់លិខិតអនុញ្ញាតសាងសង់
- យោងលិខិតលេខ ១០៨ សជណ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ក្រសួងមហាផ្ទៃ ។

## <u>សំរេច</u>

**ប្រការ ១ :** កំណត់បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដូចខាងក្រោម ÷

ក- បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់សាលាខេត្ត ក្រុង

សំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើតាមរយៈអាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ ស្រុក ខណ្ឌ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ឬអង្គភាពពាក់ព័ន្ធក្នុង

ករណីចាំបាច់ ហើយបញ្ជូនសំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដោយមានភ្ជាប់នូវយោបល់ និងមូលវិចាររបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ទៅសាលាខេត្ត ក្រុង ដើម្បីពិនិត្យ និងសំរេច ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ ដោយកំណត់ដូចខាងក្រោម ៖

- ម្ចាស់សំណើត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ស្រុក ខណ្ឌ ដោយឡែកចំពោះក្រុងភ្នំពេញ ម្ចាស់សំណើត្រូវដាក់ពាក្យសុំនៅការិយាល័យរដ្ឋបាលនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ។ ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង រយៈពេលយ៉ាងយូរ ២៥ (ម្ភៃប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតរួមទាំងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ស្រុក ខណ្ឌ និងនៅសាលាខេត្ត ក្រុង រយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ សរុបទាំងអស់ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ I)
- ម្ចាស់សំណើត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន បិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។ ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង រយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ II សន្លឹក ៣)
- ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតបិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង រយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ II សន្លឹក ៤) ។

**ខ-វិធីវិធីនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

សាលាខេត្ត ក្រុង ត្រូវបញ្ជូនសំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដោយភ្ជាប់ជាមួយនូវលិខិតដែលជាយោបល់របស់សាលាខេត្ត ក្រុង មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យ និងសំរេចក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ដោយមិនគិតពីរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការរបស់សមត្ថកិច្ចសាលាខេត្ត ក្រុង ដោយកំណត់ដូចខាងក្រោម ៖

- ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅអគ្គនាយកដ្ឋានរដ្ឋបាល រយៈពេលយ៉ាងយូរ ១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ I សន្លឹក ៦)

Please Limit Bribe

- ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម រយៈពេលយ៉ាងយូរ ១២ (ដប់ពីរ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ I សន្លឹក ៦)
- ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅអគ្គនាយកដ្ឋានសំណង់ រយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ ស្របពេលនៃការពិនិត្យរបស់អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម (ដូចមានចែងក្នុងឧបសម្ព័ន្ធ I សន្លឹក ៧)
- ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅខុទ្ទកាល័យទេសរដ្ឋមន្ត្រី រយៈពេលយ៉ាងយូរ ២ (ពីរ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ I សន្លឹក ១)
- ម្ចាស់សំណើត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន បិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ នៅនាយកដ្ឋានសំណង់នៃអគ្គនាយកដ្ឋានសំណង់ ។ ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន នៅអគ្គនាយកដ្ឋានសំណង់ រយៈពេលយ៉ាងយូរ ៨ (ប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ II សន្លឹក១)
- ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតបិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ នៅអគ្គនាយកដ្ឋានសំណង់ រយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ II សន្លឹក ២) ។

គ- និតិវិធីនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវបានកំណត់ដូចខាងក្រោម

- រយៈពេលពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ គិតចាប់ពីថ្ងៃដែលរាល់លិខិតស្នាមភ្ជាប់មកជាមួយនឹងពាក្យសុំលិខិតអនុញ្ញាតសាងសង់ បានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវ ហើយម្ចាស់សំណើទទួលបានបង្កាន់ដៃទទួលពាក្យសុំ
- ក្នុងករណីសំណុំឯកសារនៃពាក្យសុំមានលក្ខណៈខ្វះខាតឬខុសឆ្គង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ឬអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និងអគ្គនាយកដ្ឋានសំណង់ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកស្នើសុំឱ្យបំពេញបន្ថែម ឬកែតម្រូវ។ រយៈពេលពិនិត្យ និងសំរេចដែលជាសមត្ថកិច្ចសាលាខេត្ត ក្រុង ឬក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លើការបំពេញបន្ថែម ឬកែតម្រូវលើសំណុំឯកសារនៃពាក្យសុំ ត្រូវគិតជាថ្មី ចាប់ពីថ្ងៃដាក់ឡើងវិញនូវពាក្យសុំលិខិតអនុញ្ញាតសាងសង់
- ក្នុងករណីការពិនិត្យ និងសំរេចលើសំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់ មានការអូសបន្លាយពេលវេលាលើសពីការកំណត់ ដោយគ្មានមូលហេតុសមស្រប មន្ត្រីពាក់ព័ន្ធត្រូវទទួលខុសត្រូវចំពោះម្ចាស់សំណើ និងច្បាប់ជាធរមាន។

Phear/Lunit Brbut

**ប្រការ ២:** នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ អស់លោក និង លោកស្រី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គ្រប់ខេត្ត ក្រុង ត្រូវអនុវត្ត សេចក្តីសំរេចនេះ តាមភារៈកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គ្រប់សាលាខេត្ត ក្រុង (ដើម្បីសហការអនុវត្ត)
- ដូចប្រការ ២ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

Phea: Limit Bribu:

ឧបសម្ព័ន្ធ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អគ្គនាយកដ្ឋានសំណង់

នាយកដ្ឋានសិក្សាគំរោងប្លង់

# បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំ

# លិខិតអនុញ្ញាតសាងសង់

**សន្លឹក ១**

## បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់ សាលាខេត្ត ក្រុង និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់




កំណត់សំគាល់:

-សន្លឹក ៨ ត្រូវរៀបចំដោយសាលាខេត្ត ក្រុង

៧

**<u>សន្លឹក ២</u>**

## បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ



**សន្លឹក ៣**

# បរិបថនៃការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់
# នៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង




កំណត់សំគាល់:

- អាស្រ័យទៅតាមសំណុំបញ្ហាការងារបច្ចេកទេសជាក់ស្តែង ការិយាល័យ សុរិយោដី និង ភូមិសាស្ត្រនឹងត្រូវចាត់ចែងអនុវត្តការងារតាមជំនាញ ។

**សន្លឹក ៤**

# បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់
# នៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តសៀមរាប




**កំណត់សំគាល់:**

- អាស្រ័យទៅតាមសំណូមពរការងារបច្ចេកទេសជាក់ស្តែង ការិយាល័យសុរិយោដី និង ភូមិសាស្ត្រនឹងត្រូវចាត់អោយអនុវត្តការងារតាមមុខជំនាញ ។
- តាមការប្រជុំ ឯកភាពគ្នាទៅសាលាខេត្តសៀមរាបកាលពីថ្ងៃទី ២៨ ខែ មិនា ឆ្នាំ២០០០ គំរោងប្លង់ដែលត្រូវដាក់ឆ្លងអាជ្ញាធរអប្សរា មានទំហំធំជាង ៣០០០ម² ។ ក្នុងការអនុវត្តជាក់ស្តែង កន្លងមកនេះ គំរោងប្លង់ដែលមានទំហំ ស្មើឬតូចជាងនេះ មិនត្រូវបានដាក់ឆ្លងអាជ្ញាធរអប្សរាទេ ។

**សន្លឹក ៥**

## បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់សាលាខេត្ត ក្រុង



**សន្លឹក ៦**

# បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់
# នៅក្នុងអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម



<u>**សន្លឹក ៧**</u>

## បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅក្នុងអគ្គនាយកដ្ឋានសំណង់



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋានសំណង់
នាយកដ្ឋានសិក្សាគំរោងប្លង់

# រយៈពេលនៃការពិនិត្យ និងសំរេចលើពាក្យសុំ លិខិតអនុញ្ញាតសាងសង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋានសំណង់
នាយកដ្ឋានសិក្សាគំរោងប្លង់

**ឧបសម្ព័ន្ធ**

## រយៈពេលនៃការពិនិត្យ និង សំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់សាលាខេត្ត ក្រុង និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម

| ល.រ | សមត្ថកិច្ច | ចំនួនថ្ងៃ | ថ្ងៃធ្វើការ 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | 32 | 33 | 34 | 35 | 36 | 37 | 38 | 39 | 40 | 41 | 42 | 43 | 44 | 45 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | មន្ទីរ ដនសស | 25 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 2 | សាលាខេត្ត ក្រុង | 5 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 3 | អគ្គនាយកដ្ឋានរដ្ឋបាល | 0.5 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 4 | អគ្គនាយកដ្ឋាន ដ ន | 12 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 5 | អគ្គនាយកដ្ឋានសំណង់ | 10 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 6 | ខុទ្ទកាល័យទេសរដ្ឋមន្ត្រី | 2 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 7 | អគ្គ.រដ្ឋបាល ( ប្រគល់ឯកសារ) | 0.5 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | **រយៈពេលសរុប** | 45 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

**កំណត់សំគាល់ពីប្រភេទការងារសំខាន់ៗតាមសមត្ថកិច្ចនីមួយៗ**

១- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ពិនិត្យឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ រួចធ្វើលិខិតផ្តល់មតិយោបល់បញ្ជូនទៅសាលាខេត្ត ក្រុង ដោយមានភ្ជាប់សម្រាំឯកសារនៃពាក្យសុំ

២- សាលាខេត្ត ក្រុង ពិនិត្យឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ហើយធ្វើលិខិតផ្តល់មតិយោបល់បញ្ជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ពិនិត្យសំរេច

៣- អគ្គនាយកដ្ឋានរដ្ឋបាល ពិនិត្យលើលក្ខណៈគតិយុត្តិនៃឯកសារ ចុះលេខ ចុះកាលបរិច្ឆេទចូល ប្រថាប់ត្រា និងបញ្ជូនទៅអគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម

៤- អគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម បញ្ជូនសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ទៅអគ្គនាយកដ្ឋានសំណង់ ០១ច្បាប់ ដើម្បីពិនិត្យ និង ផ្តល់យោបល់ក្នុងពេលស្របគ្នា និង ធ្វើសំយោគមតិរបស់អគ្គនាយកដ្ឋានជំនាញទាំងពីរ ដាក់ជូនថ្នាក់ដឹកនាំក្រសួង ពិនិត្យសំរេច

៥- អគ្គនាយកដ្ឋានសំណង់ពិនិត្យ និង ផ្តល់យោបល់ រួចបញ្ជូនសំណុំឯកសារស្នើសុំទៅអគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម ដើម្បីធ្វើសំយោគមតិរបស់អគ្គនាយកដ្ឋាន ជំនាញទាំងពីរ រួចដាក់ជូនឯកឧត្តមទេសរដ្ឋមន្ត្រី ពិនិត្យសំរេច និង ចុះហត្ថលេខា យល់ព្រម រឺ មិនយល់ព្រម

៦- ខុទ្ទកាល័យទេសរដ្ឋមន្ត្រី ពិនិត្យផ្ទៀងផ្ទាត់ លើសំណុំឯកសារ ហើយធ្វើកំណត់បង្ហាញ ដាក់ជូនឯកឧត្តមទេសរដ្ឋមន្ត្រី ពិនិត្យសំរេច និង ចុះហត្ថលេខា យល់ព្រម រឺមិនយល់ព្រម

៧- អគ្គនាយកដ្ឋានរដ្ឋបាល បន្ទាប់ពីក្រសួងយល់ព្រម ឬ មិនយល់ព្រមផ្តល់លិខិតអនុញ្ញាតសាងសង់ ជូនម្ចាស់សំណើ អគ្គនាយកដ្ឋានរដ្ឋបាលមានភារកិច្ចបែងចែកសំណុំឯកសារតាមមុខការ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋានសំណង់
នាយកដ្ឋានសិក្សាគំរោងប្លង់

**សន្លឹក២**

## រយៈពេលនៃការពិនិត្យ និង សំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់
## នៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ

| ល.រ | សមត្ថកិច្ច | ចំនួនថ្ងៃ | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ថ្ងៃធ្វើការ | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 1 | ការិយាល័យរដ្ឋបាល និង ថ្នាក់ដឹកនាំមន្ទីរ | 8 | ■ | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| 2 | ការិយាល័យ ដ.ន.ស.ភ | 6 | | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | |
| 3 | ការិយាល័យ សុរិយោដី-ការិយាល័យបច្ចេកទេសសុរិយោដី | 4 | | | | | | | | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | |
| 4 | ការិយាល័យសំណង់-ការិយាល័យ ដ.ន | 7 | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | |
| 5 | អង្គភាពពាក់ព័ន្ធ | 7 | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | |
| 6 | សាលាក្រុងភ្នំពេញ | 5 | | | | | | | | | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ |
| | **រយៈពេលសរុប** | 30 | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

**គំនត់សំគាល់អំពីមុខគោលការណ៍សំខាន់ៗតាមសមត្ថកិច្ចនីមួយៗ**

១- ពិនិត្យលក្ខណៈគ្រប់គ្រាន់និងភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Checklist)
- ចុះហត្ថលេខាសង្ខេបលើតារាងត្រួតពិនិត្យ (Checklist)
- ចុះលេខ ចុះកាលបរិច្ឆេទចូលនិងប្រថាប់ត្រា
- ចេញបង្កាន់ដៃ ( បើឯកសារគ្រប់គ្រាន់ )
- បញ្ជូនទៅអនុប្រធានមន្ទីរទទួលបន្ទុករដ្ឋបាលហើយជាបញ្ជូនទៅការិយាល័យ ដនសភ ខណ្ឌ ដើម្បីពិនិត្យ

២- ពិនិត្យលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Checklist)
- ចុះហត្ថលេខាសង្ខេបលើតារាងត្រួតពិនិត្យ (Checklist)
- ចុះលេខ ចុះកាលបរិច្ឆេទចូល និងប្រថាប់ត្រា
- បញ្ជូនទៅអនុការិយាល័យ ហើយបញ្ជូនទៅប្រធានការិយាល័យ ដើម្បីបញ្ជូនទៅផ្នែកជំនាញតាមបុគ្គល
- ផ្នែកសុរិយោដី និង ផ្នែក ដនស ចុះពិនិត្យវាស់វែង ស្ទាបស្ទង់ទីតាំងក្បាលដី ដើម្បីធ្វើសាលាកប័ត្រ ដី និង គណនាថ្លៃក្រឡា

៣- ពិនិត្យលើឯកសារដីកាន់កាប់នេះ មានពាក់ព័ន្ធការហាមឃាត់ ឬ ជីមានទំនាស់
- ពិនិត្យសំណុំឯកសារការវាស់វែងដី ទំហំដី និង ទិតាំងដី
- ការិយាល័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទទួលលើការងារបង់ពន្ធដី និង បង់កម្រៃសេវាសុរិយោដី

៤- ពិនិត្យលើលក្ខណៈនគរូបនីយកម្ម គម្លាត កំពស់ តំបន់ និង សន្ទស្សន៍ នៃការដែលប្រើប្រាស់ដី
- ពិនិត្យលើលក្ខណៈបច្ចេកទេសសំណង់ សោភ័ណភាព វចនាបថស្ថាបត្យកម្ម និង ប្លង់ស្ថាបត្យកម្ម

៥- ពិនិត្យលើគំរោងសាងសង់មានការពាក់ព័ន្ធបញ្ហាបរិស្ថាន ទេសចរណ៍ ប្រឡាយ លូទឹក តំបន់ហាមឃាត់

៦- ពិនិត្យលក្ខណៈគ្រប់គ្រាន់និងភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Checklist)
- ចុះហត្ថលេខាសង្ខេប ចុះលេខចុះកាលបរិច្ឆេទចូល ប្រថាប់ត្រា
- ពិនិត្យសំរេចចុះហត្ថលេខាយល់ព្រម រឺ មិនយល់ព្រម ក្នុងករណីសមត្ថកិច្ចរបស់ ក្នុងការណែនាំស្នើសុំលិខិតអនុញ្ញាតសាងសង់ ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ត្រូវធ្វើលិខិតផ្តល់មតិយោបល់ និង ភ្ជាប់ជាមួយសំណុំឯកសារពាក្យសុំផ្ញើជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ពិនិត្យសំរេច ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋានសំណង់
នាយកដ្ឋានសិក្សាគំរោងប្លង់

សន្លឹក៣

## រយៈពេលនៃការពិនិត្យ និង សំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់
## នៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង

| ល.រ | សមត្ថកិច្ច | ចំនួនថ្ងៃ | ថ្ងៃធ្វើការ 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | ការិយាល័យ ដ.ន.ស.ក | 6 | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | |
| 2 | សាលាស្រុក ខណ្ឌ | 3 | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | |
| 3 | ការិយាល័យរដ្ឋបាល និងថ្នាក់ដឹកនាំមន្ទីរ | 9 | | | | | | | | | | ■ | ■ | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| 4 | ការិយាល័យសំណង់-ការិយាល័យ ដ.ន | 7 | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | |
| 5 | អង្គភាពពាក់ព័ន្ធ | 4 | | | | | | | | | | | | ■ | ■ | ■ | ■ | | | | | | | | | | | | | | | |
| 6 | សាលាខេត្ត ក្រុង | 5 | | | | | | | | | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ |
| | **រយៈពេលសរុប** | 30 | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

កំណត់សំគាល់អំពីប្រតិបត្តិការងារតាមសមត្ថកិច្ចនីមួយៗ

១- ម្ចាស់សំណើដាក់ពាក្យសុំតាមរយៈរដ្ឋបាលមូលដ្ឋាន
- បញ្ជូនទៅការិយាល័យ ដនសក
- ពិនិត្យលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Checklist)
- ចុះហត្ថលេខាសង្ខេបលើតារាងត្រួតពិនិត្យ (Checklist)
- ចុះលេខ ចុះកាលបរិច្ឆេទចូល និងប្រថាប់ត្រា
- ចេញបង្កាន់ដៃ ។ បើឯកសារគ្រប់គ្រាន់ ។
- ពិនិត្យលក្ខណៈគតិយុត្តនៃឯកសារ
- ចុះពិនិត្យវាស់វែងដី គូរប្លង់ដីកាន់កាប់
- ពិនិត្យទីតាំងព្រំដី និង ធ្វើកំណត់ហេតុអង្កេតជាមួយដីជិតខាង
- ធ្វើគំនូរព្រាងបញ្ជាក់ពីតំបន់ ទីតាំងសាងសង់ និងគម្លាតអគារ

២- ចុះលេខ ចុះកាលបរិច្ឆេទចូលនិងប្រថាប់ត្រា
- ពិនិត្យលក្ខណៈគតិយុត្តនៃឯកសារ
- បញ្ជាក់លើលិខិតស្នាមផ្សេងៗ

៣- ពិនិត្យលក្ខណៈគ្រប់គ្រាន់និងភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Checklist)
- ចុះហត្ថលេខាសង្ខេបលើតារាងត្រួតពិនិត្យ (Checklist)
- ចុះលេខចុះកាលបរិច្ឆេទចូល និងប្រថាប់ត្រា
- ពិនិត្យលក្ខណៈគតិយុត្តនៃឯកសារ
- ពិនិត្យទំរង់ការរដ្ឋបាលនៃឯកសារ
- ធ្វើលិខិតផ្តល់មតិយោបល់ជូនសាលាខេត្ត ក្រុង

៤- ពិនិត្យលើគម្រោងនិយមបញ្ញត្តិ គម្លាតអគារ កំពស់ សន្ទស្សន៍នៃការប្រើប្រាស់ដី មុខងារ និង តំបន់ ថាតើត្រូវតាមប្លង់គោល និង ប្លង់ប្រើប្រាស់ដីផ្សេងៗ បទបញ្ញត្តិនៃការប្រើប្រាស់ដីឬទេ ?
- ពិនិត្យលក្ខណៈបច្ចេកទេសនៃសំណង់ ដូចជា សោភ័ណភាព របៀបផ្សារភ្ជាប់ប្រព័ន្ធ ប្រព័ន្ធលំហូរ កំណើនចរាចរណ៍ ផ្លូវ ទឹក និង បទដ្ឋានប្រើប្រាស់សំភារៈសំណង់

៥- ពិនិត្យលើលក្ខណៈបច្ចេកទេស អំពាវនាវស្នើសុំស្ថិតនៅតំបន់ពាក់ព័ន្ធ ពាក់ព័ន្ធ បញ្ហាបរិស្ថាន ទេសចរណ៍ ប្រឡាយ លូទឹក ផ្លូវថ្នល់ ឬតំបន់បេតិកភ័ណ្ឌ ។ល។

៦- ពិនិត្យលក្ខណៈគ្រប់គ្រាន់និងភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Checklist)
- ចុះហត្ថលេខាសង្ខេបលើតារាងត្រួតពិនិត្យ (Checklist)
- ចុះលេខ ចុះកាលបរិច្ឆេទចូល និងប្រថាប់ត្រា
- ពិនិត្យសំណុំឯកសារដែលទទួលបានពីគ្រប់ស្ថាប័ន តាមសមត្ថកិច្ចរបស់ខ្លួន ក្នុងករណីសំណើសុំលិខិតអនុញ្ញាតសាងសង់ ជាសមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ត្រូវធ្វើលិខិតផ្តល់មតិយោបល់ភ្ជាប់ជាមួយសំណុំឯកសារស្នើសុំ ហើយធ្វើជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ពិនិត្យសំរេច ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋានសំណង់
នាយកដ្ឋានសិក្សាគំរោងប្លង់

សន្លឹក៤

## រយៈពេលនៃការពិនិត្យ និង សំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅក្នុងមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តសៀមរាប

| ល.រ | សមត្ថកិច្ច | ចំនួនថ្ងៃ | ថ្ងៃធ្វើការ | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
| 1 | ការិយាល័យ ដ.ន.ស.ភ | 6 | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | |
| 2 | សាលាស្រុក ខណ្ឌ | 3 | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | |
| 3 | ការិយាល័យរដ្ឋបាល និងថ្នាក់ដឹកនាំមន្ទីរ | 9 | | | | | | | | | | ■ | ■ | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| 4 | ការិយាល័យសំណង់-ការិយាល័យ ដ.ន | 7 | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | |
| 5 | អាជ្ញាធរអប្សរា | 7 | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | |
| 6 | អង្គភាពពាក់ព័ន្ធ | 4 | | | | | | | | | | | | ■ | ■ | ■ | ■ | | | | | | | | | | | | | | | |
| 7 | សាលាខេត្តសៀមរាប | 5 | | | | | | | | | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ |
| | **រយៈពេលសរុប** | 30 | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

**កំណត់សំគាល់អំពីមុខងារការងារសំខាន់ៗតាមសមត្ថកិច្ចនីមួយៗ**

១- ប្រមូលសំណើដាក់ពាក្យសុំតាមរយៈអាជ្ញាធរមូលដ្ឋាន
- បញ្ជូនទៅការិយាល័យ ដនសក
- ពិនិត្យលក្ខណៈគ្រប់គ្រាន់និងភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Checklist)
- ចុះហត្ថលេខាសង្ខេបលើតារាងត្រួតពិនិត្យ (Checklist)
- ចុះលេខ ចុះកាលបរិច្ឆេទចូលនិងប្រថាប់ត្រា
- ចេញបង្កាន់ដៃ (បើឯកសារគ្រប់គ្រាន់)
- ពិនិត្យលក្ខណៈគតិយុត្តិនៃឯកសារ
- ចុះពិនិត្យវាស់វែងដី គូរប្លង់ដីកាន់កាប់
- ពិនិត្យទីតាំងព្រំដី និង ធ្វើកំណត់ហេតុអង្កេតជាមួយដីជិតខាង
- ផ្ញើរលោកប្រធានក្រុមប្រឹក្សាធានាគំរូគំនិតទីតាំងសាងសង់ និង ... កម្មាករ

២- ចុះលេខ ចុះកាលបរិច្ឆេទចូលនិងប្រថាប់ត្រា
- ពិនិត្យលក្ខណៈគតិយុត្តនៃឯកសារ
- បញ្ជាក់លើលិខិតស្នាមផ្សេងៗ

៣- ពិនិត្យលក្ខណៈគ្រប់គ្រាន់និងភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Checklist)
- ចុះហត្ថលេខាសង្ខេបលើតារាងត្រួតពិនិត្យ (Checklist)
- ចុះលេខ ចុះកាលបរិច្ឆេទចូលនិងប្រថាប់ត្រា
- ពិនិត្យលក្ខណៈគតិយុត្តនៃឯកសារ
- ពិនិត្យទំរង់ការផ្លូវច្បាប់នៃឯកសារ
- ព្រាងលិខិតផ្តល់មតិយោបល់ជូនសាលាខេត្ត ក្រុង

៤- ពិនិត្យលើនិយ័តបញ្ញត្តិ កម្ពស់អគារ កំពស់ សន្ទស្សន៍នៃការប្រើប្រាស់ដី បុរេអា និង តំបន់ ត្រូវតាមប្លង់គោល និង ប្លង់ប្រើប្រាស់ដីផ្សេងៗ បទបញ្ជានៃការប្រើប្រាស់ដីធ្លី
- ពិនិត្យលក្ខណៈបច្ចេកទេសនៃសំណង់ ដូចជា សោភ័ណភាព រចនាបថស្ថាបត្យកម្ម ប្លង់គ្រប់ជាន់ គំហើញអគារទាំង ៤ទិស ពុះបណ្តោយ ពុះទទឹង និង បទដ្ឋានប្រើប្រាស់សំភារៈសំណង់

៥- ពិនិត្យលើនិយ័តបញ្ញត្តិ ដែលបានកំណត់ក្នុងការរៀបចំការសាងសង់ និងការអភិវឌ្ឍន៍ ទៅតំបន់សៀមរាបអង្គរ

៦- ពិនិត្យលើលក្ខណៈបច្ចេកទេស តំរោងស្ថិតនៅតំបន់ដែលមានពាក់ព័ន្ធ បញ្ហាបរិស្ថាន មេសធរណ៍ ប្រឡាយ លូទឹក ផ្លូវថ្នល់ ឬតំបន់បេតិកភណ្ឌ

៧- ពិនិត្យលក្ខណៈគ្រប់គ្រាន់និងភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Checklist)
- ចុះហត្ថលេខាសង្ខេបលើតារាងត្រួតពិនិត្យ (Checklist)
- ចុះលេខ ចុះកាលបរិច្ឆេទចូល និងប្រថាប់ត្រា
- ពិនិត្យសំរេចចុះហត្ថលេខាយល់ព្រម ឬ មិនយល់ព្រមក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន ក្នុងករណីគំរោងស្នើសុំលិខិតអនុញ្ញាតសាងសង់ជាសមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ត្រូវធ្វើលិខិតផ្តល់មតិយោបល់ភ្ជាប់ជាមួយសំណុំឯកសារស្នើសុំ ហើយផ្ញើជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពិនិត្យសំរេច។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋានសំណង់
នាយកដ្ឋានសិក្សាគំរោងប្លង់

សន្លឹក៥

## រយៈពេលនៃការពិនិត្យ និង សំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់
## ដែលជាសមត្ថកិច្ច ខេត្ត ក្រុង

| ល.រ | សមត្ថកិច្ច | ចំនួនថ្ងៃ | ថ្ងៃធ្វើការ | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
| 1 | មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់និងសុរិយោដីខេត្ត ក្រុង | 25 | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| 2 | សាលាខេត្ត ក្រុង | 5 | | | | | | | | | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ |
| | **រយៈពេលសរុប** | 30 | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

**គំនូសសំគាល់អំពីប្រភេទការងារសំខាន់ៗតាមសមត្ថកិច្ចនីមួយៗ**

១- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង មានតួនាទីភារៈកិច្ចពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ចាប់ពីពេលឯកសារដាក់ចូលផ្នែករដ្ឋបាល ឬ ការិយាល័យរដ្ឋបាល រួមមាន :

- ភាពគ្រប់គ្រាន់នៃឯកសារ
- ចុះហត្ថលេខាសង្ខេបលើតារាងត្រួតពិនិត្យ (Checklist)
- ចុះលេខ ចុះកាលបរិច្ឆេទចូល និងប្រថាប់ត្រា
- ចេញបង្កាន់ដៃ ( បើឯកសារគ្រប់គ្រាន់ )
- ពិនិត្យក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន និង ធ្វើលិខិតផ្តល់មតិយោបល់ផ្ញើជូនសាលាខេត្ត ក្រុង ដោយភ្ជាប់សំណុំឯកសារ និង គំរោងប្លង់

២- ពិនិត្យលក្ខណៈគ្រប់គ្រាន់ និងភាពគ្រប់គ្រាន់តាមតារាងត្រួតពិនិត្យ (Checklist) ចុះហត្ថលេខាសង្ខេប ប្រថាប់ត្រាចុះ ចុះកាលបរិច្ឆេទ

- ពិនិត្យសំរេច ចុះហត្ថលេខាយល់ព្រម ឬ មិនយល់ព្រម ក្នុងសមត្ថកិច្ចរបស់ខ្លួន ក្នុងការផ្តល់លិខិតស្នើសុំលិខិតអនុញ្ញាតសាងសង់ ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ត្រូវធ្វើលិខិតផ្តល់យោបល់ និង ភ្ជាប់ដោយគំរោងប្លង់ផ្ញើជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ពិនិត្យសំរេច ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋានសំណង់
នាយកដ្ឋានសិក្សាគំរោងប្លង់

សន្លឹក៦

# រយៈពេលនៃការពិនិត្យ និង សម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅក្នុងអគ្គនាយករៀបចំដែនដី និងនគរូបនីយកម្ម និងខុទ្ទកាល័យទេសរដ្ឋមន្ត្រី

| ល.រ | សមត្ថកិច្ច | ចំនួនថ្ងៃ | ថ្ងៃធ្វើការ | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
| 1 | នាយកដ្ឋានស្រាវជ្រាវបទប្បញ្ញត្តិ | 0.5 | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 2 | នាយកដ្ឋាននគរូបនីយកម្ម | 4 | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | |
| 3 | អគ្គនាយក និងអគ្គនាយករងនៃអគ្គនាយកដ្ឋាន ដ.ន | 3 | | | | | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | |
| 4 | រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការទទួលបន្ទុក | 3 | | | | | | | | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | |
| 5 | នាយកដ្ឋាននគរូបនីយកម្ម | 1 | | | | | | | | | | | ■ | ■ | | | | | | | | | | | | | | | | | | |
| 6 | នាយកដ្ឋានស្រាវជ្រាវបទប្បញ្ញត្តិ | 0.5 | | | | | | | | | | | | ■ | | | | | | | | | | | | | | | | | | |
| | **រយៈពេលសរុប** | **12** | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 7 | ខុទ្ទកាល័យទេសរដ្ឋមន្ត្រី | 2 | | | | | | | | | | | | | ■ | ■ | | | | | | | | | | | | | | | | |
| 8 | អគ្គនាយកដ្ឋានរដ្ឋបាល | 1 | | | | | | | | | | | | | | | ■ | | | | | | | | | | | | | | | |
| | **រយៈពេលសរុប** | **3** | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

**កំណត់សំគាល់អំពីប្រភេទការងារសំខាន់ៗតាមសមត្ថកិច្ចនីមួយៗ**

១- ពិនិត្យលក្ខណៈគ្រប់គ្រាន់ និង ភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Checklist) និង ចុះហត្ថលេខាសង្ខេប
- ចុះលេខ ចុះកាលបរិច្ឆេទចូល និង ប្រថាប់ត្រា
- បញ្ជូនទៅអគ្គនាយកដ្ឋានសំណង់ និង អគ្គនាយកដ្ឋាននគរូបនីយកម្ម ដើម្បីពិនិត្យ

២- ពិនិត្យលក្ខណៈគតិយុត្តិនៃឯកសារ
- ពិនិត្យគំលាតអគារ ការរៀបចំប្លង់ក្នុងដីឡូតិ៍
- គណនាសន្ទស្សន៍នៃការប្រើប្រាស់ដី
- ហេដ្ឋារចនាសម្ព័ន្ធ ពិនិត្យលើខ្សែទុរគមនាគមន៍ មានផ្លូវថ្នល់ លូទឹក ទីកស្អាត អគ្គិសនី... ។ល។
- ដំណោគមតិរបស់អគ្គនាយកដ្ឋានជំនាញទាំងពីរ និង ព្រាងលិខិតអនុញ្ញាតវិ មិនអនុញ្ញាតសាងសង់ ដាក់ជូនឯកឧត្តមទេសរដ្ឋមន្ត្រី ពិនិត្យសំរេច

៣- អគ្គនាយករងទទួលបន្ទុកពិនិត្យលើឯកសារគតិយុត្តិ និងផ្តល់មតិលើលក្ខណៈបច្ចេកទេស ដាក់ជូនអគ្គនាយក
- អគ្គនាយកពិនិត្យ និងផ្តល់យោបល់ជូនអនុរដ្ឋលេខាធិការ និងរដ្ឋលេខាធិការទទួលបន្ទុក ដើម្បីផ្តល់មតិបន្ថែម

៤- អនុរដ្ឋលេខាធិការទទួលបន្ទុកពិនិត្យ និងផ្តល់មតិលើលក្ខណៈបច្ចេកទេសជូនរដ្ឋលេខាធិការ
- រដ្ឋលេខាធិការទទួលបន្ទុកពិនិត្យ និងផ្តល់មតិ សំរាប់អគ្គនាយកដ្ឋាន រៀបចំដែនដី និង នគរូបនីយកម្ម ដាក់ជូនឯកឧត្តមទេសរដ្ឋមន្ត្រី ពិនិត្យ និង សំរេច

៥- នាយកដ្ឋាននគរូបនីយកម្មទទួលការកិច្ចធ្វើបតិសំយោគ របស់អគ្គនាយកដ្ឋានជំនាញទាំង ០២ និង ព្រាងលិខិតអនុញ្ញាតសាងសង់ ដាក់ជូនអគ្គនាយករៀបចំដែនដី និង នគរូបនីយកម្ម ពិនិត្យ និង ចុះហត្ថលេខាសង្ខេប

៦- ពិនិត្យភាពគ្រប់គ្រាន់នៃឯកសារ
- ចុះលេខចេញ និង ប្រថាប់ត្រា
- បញ្ជូនទៅខុទ្ទកាល័យទេសរដ្ឋមន្ត្រី

៧- ពិនិត្យភាពគ្រប់គ្រាន់ការឯកសារ
- ធ្វើកំណត់បង្ហាញរឿងដាក់ជូនឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកឧត្តមទេសរដ្ឋមន្ត្រី ចុះហត្ថលេខាយល់ព្រម ឬ មិនយល់ព្រម
- ប្រថាប់ត្រា

៨- ចុះលេខចេញ
- ប្រគល់លិខិតអនុញ្ញាតសាងសង់ និង ប្លង់ស្ថាបត្យកម្ម ក្នុងករណីយល់ព្រម ជូនសាមីជន ត្រូវ
- ប្រគល់លិខិតអនុញ្ញាតសាងសង់ និង ប្លង់ទុកជាឯកសារ នៅអគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម ០១ច្បាប់ និង អគ្គនាយកដ្ឋានសំណង់ ០១ច្បាប់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋានសំណង់
នាយកដ្ឋានសិក្សាគំរោងប្លង់

សន្លឹក៧

# រយៈពេលនៃការពិនិត្យ និង សំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់
# នៅក្នុងអគ្គនាយកដ្ឋានសំណង់

| ល.រ | សមត្ថកិច្ច | ចំនួនថ្ងៃ | ថ្ងៃធ្វើការ 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | នាយកដ្ឋានសិក្សាគំរោងប្លង់ | 4 | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | |
| 2 | អគ្គនាយក និងអគ្គនាយករងនៃអគ្គនាយកដ្ឋានសំណង់ | 2 | | | | | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | |
| 3 | រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការទទួលបន្ទុក | 3 | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | |
| 4 | នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ | 1 | | | | | | | | | | ■ | | | | | | | | | | | | | | | | | | | | |
| | **រយៈពេលសរុប** | 10 | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

**កំណត់សំគាល់ពីកិច្ចការដែលត្រូវធ្វើតាមសមត្ថកិច្ចនីមួយៗ**

១-ពិនិត្យលក្ខណៈគ្រប់គ្រាន់ និង ភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Checklist)
- ចុះលេខ ចុះកាលបរិច្ឆេទចូល និង ប្រថាប់ត្រា
- ដាក់ជូនអគ្គនាយក ដើម្បីចារបញ្ជូនមកនាយកដ្ឋានពិនិត្យ
- នាយកដ្ឋានចារបញ្ជូនមកការិយាល័យស្ថាបត្យកម្ម និងការិយាល័យវិស្វកម្ម និងកិច្ចការតំលៃ ដើម្បីមុខការ
  - ពិនិត្យលក្ខណៈគតិយុត្តនៃឯកសារ
  - ពិនិត្យទំនាក់ការផ្ទៀងផ្ទាត់នៃឯកសារ និង សំណើ
  - ពិនិត្យលើប្លង់ ស្ថាបត្យកម្ម
  - ពិនិត្យលើប្លង់គ្រឿងផ្គុំសំណង់ និង កិច្ចការតំលៃ ( បើសិនមាន )
- នាយកដ្ឋានធ្វើកំណត់បង្ហាញស្ថិតិលក្ខណៈវិនិច្ឆ័យនៃគំរោងស្នើសុំ រួចដាក់ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពិនិត្យ និង ផ្តល់មតិ

២-អគ្គនាយករងទទួលបន្ទុក ពិនិត្យលើសំណុំឯកសារ និងផ្តល់មតិដាក់ជូនអគ្គនាយក
- អគ្គនាយកពិនិត្យ និង ផ្តល់យោបល់ជូនអនុរដ្ឋលេខាធិការ និង រដ្ឋលេខាធិការ ដើម្បីពិនិត្យសំរេច

៣-អនុរដ្ឋលេខាធិការទទួលបន្ទុកពិនិត្យ និង ផ្តល់មតិលើលក្ខណៈបច្ចេកទេសជូនរដ្ឋលេខាធិការ
- រដ្ឋលេខាធិការទទួលបន្ទុកពិនិត្យ និង សំរេចក្នុងសមត្ថកិច្ច របស់អគ្គនាយកដ្ឋានសំណង់ គោរពជូនឯកឧត្តមទេសរដ្ឋមន្ត្រី ពិនិត្យនិងសំរេច

៤- នាយកដ្ឋានមានភារកិច្ច ប្រថាប់ត្រាចុះលេខ ចុះកាលបរិច្ឆេទចេញ បញ្ជូនទៅអគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម ដើម្បីសំយោគមតិដាក់ជូនឯកឧត្តមទេសរដ្ឋមន្ត្រី ។

ឧបសម្ព័ន្ធ II

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អគ្គនាយកដ្ឋានសំណង់
នាយកដ្ឋានសំណង់

# បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំ
# លិខិតអនុញ្ញាតបើក និងបិទការដ្ឋានសាងសង់

សន្លឹកទី៦

**បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់**
**ដែលជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**




**កំណត់សំគាល់ :**

-មិនរាប់បញ្ចូលចំនួនថ្ងៃដែលសុំលិខិតបេសកកម្ម

-រយៈពេលខាងលើ គិតថ្ងៃធ្វើការ ។

សន្លឹកទី២

## បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតបិទការដ្ឋានសាងសង់ ដែលជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់




**កំណត់សំគាល់ :**

-មិនរាប់បញ្ចូលចំនួនថ្ងៃដែលសុំលិខិតបេសកកម្ម

-រយៈពេលខាងលើ គិតថ្ងៃធ្វើការ ។

សន្លឹកទី៣

**បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់**
**ដែលជាសមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត-ក្រុង**



សន្លឹកទី៤

### បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតបិទការដ្ឋានសាងសង់
### ដែលជាសមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត-ក្រុង



ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អគ្គនាយកដ្ឋានសំណង់

នាយកដ្ឋានសំណង់

ឧបសម្ព័ន្ធ៦

## រយៈពេលនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ ដែលជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| ល.រ | សមត្ថកិច្ច | ចំនួនថ្ងៃ | ថ្ងៃធ្វើការ ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ |
|---|---|---|---|---|---|---|---|---|---|---|
| ១ | ការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យ | ០.៥ | ■ | | | | | | | |
| ២ | ថ្នាក់ដឹកនាំនាយកដ្ឋាន | ០.៥ | ■ | | | | | | | |
| ៣ | ការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យ | ៣ | | ■ | ■ | ■ | | | | |
| ៤ | នាយកដ្ឋានសិក្សាគំរោងប្លង់ | ២ | | | | | ■ | ■ | | |
| ៥ | លោកអគ្គនាយករង | ០.៥ | | | | | | | ■ | |
| ៦ | ឯកឧត្តមអគ្គនាយក | ០.៥ | | | | | | | ■ | |
| ៧ | ឯកឧត្តមអនុរដ្ឋលេខាធិការ | ០.៥ | | | | | | | | ■ |
| ៨ | នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ | ០.៥ | | | | | | | | ■ |
| | រយៈពេលសរុប | ៨ | | | | | | | | |

**កំណត់សំគាល់អំពីប្រភេទការងារសំខាន់ៗតាមសមត្ថកិច្ចនីមួយៗ**

១-ពិនិត្យលក្ខណៈគ្រប់គ្រាន់ និងភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Check List)

-វាយត្រាចូល និងចុះលេខចូល

-ចុះហត្ថលេខាបង្រួម

-ចេញបង្កាន់ដៃ (បើឯកសារគ្រប់គ្រាន់)

-បញ្ជូនទៅថ្នាក់ដឹកនាំនាយកដ្ឋាន

២-ការពិនិត្យសំណុំឯកសារ

-ធ្វើមតិវិចារណ៍បញ្ជូនទៅការិយាល័យបច្ចេកទេស និងត្រួតពិនិត្យ ដើម្បីមុខការ

៣-ការត្រួតពិនិត្យសំណុំឯកសារពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន

-ចុះត្រួតពិនិត្យចុះវាស់វែង និងចុះបោះបង្គោល កំណត់ព្រំដល់ការដ្ឋានសាងសង់

-ពិនិត្យកិច្ចសន្យាសាងសង់រវាងម្ចាស់សំណង់ និងអ្នកម៉ៅការសាងសង់

-រៀបចំកំណត់ហេតុស្តីពីការចុះត្រួតពិនិត្យដល់ការដ្ឋានសំណង់

-រៀបចំលិខិតអនុញ្ញាតបើកការដ្ឋាន

-រូបថតជាក់ស្តែងនៅការដ្ឋានសាងសង់

៤-ការពិនិត្យពាក្យស្នើសុំ

-ពិនិត្យប្លង់គ្រឿងផ្គុំសំណង់

៥-អគ្គនាយករង ធ្វើការពិនិត្យ និងមានមតិវិចារណ៍លើកំណត់បង្ហាញសំណុំរឿង រួចបញ្ជូនទៅឯកឧត្តមអគ្គនាយក

៦-ឯកឧត្តមអគ្គនាយក ពិនិត្យ និងមានមតិវិចារណ៍លើកំណត់បង្ហាញសំណុំរឿងបញ្ជូនទៅឯកឧត្តមអនុរដ្ឋលេខាធិការ

៧-ឯកឧត្តមអនុរដ្ឋលេខាធិការពិនិត្យ និងមានមតិវិចារណ៍លើកំណត់បង្ហាញសំណុំរឿង រួចបញ្ជូនទៅឯកឧត្តមអគ្គនាយក ដើម្បីចុះហត្ថលេខាលើលិខិតអនុញ្ញាតបើកការដ្ឋាន

៨-វាយត្រាចេញ និងចុះលេខចេញ

-បញ្ជូនទៅម្ចាស់សំណើ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អគ្គនាយកដ្ឋានសំណង់

នាយកដ្ឋានសំណង់

សន្លឹក២

រយៈពេលនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតបិទការដ្ឋានសាងសង់

ដែលជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| ល.រ | សមត្ថកិច្ច | ចំនួនថ្ងៃ | ថ្ងៃធ្វើការ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១ | ការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យ | 0.៥ | ■ | | | | | |
| ២ | ថ្នាក់ដឹកនាំនាយកដ្ឋាន | 0.៥ | ■ | | | | | |
| ៣ | ការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យ | ៣ | | ■ | ■ | ■ | | |
| ៤ | លោកអគ្គនាយករង | 0.៥ | | | | | ■ | |
| ៥ | ឯកឧត្តមអគ្គនាយក | 0.៥ | | | | | ■ | |
| ៦ | ឯកឧត្តមអនុរដ្ឋលេខាធិការ | 0.៥ | | | | | | ■ |
| ៧ | នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ | 0.៥ | | | | | | ■ |
| | រយៈពេលសរុប | ៦ | | | | | | |

**កំណត់សំគាល់អំពីប្រភេទការងារសំខាន់ៗតាមសមត្ថកិច្ចនីមួយៗ**

១-ពិនិត្យលក្ខណៈគ្រប់គ្រាន់ និងភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Check List)

-វាយត្រាចូល និងចុះលេខចូល

-ចុះហត្ថលេខាបង្រួម

-ចេញបង្កាន់ដៃ (បើឯកសារគ្រប់គ្រាន់)

-បញ្ជូនទៅថ្នាក់ដឹកនាំនាយកដ្ឋាន

២-ការពិនិត្យសំណុំឯកសារ

-ធ្វើមូលវិចារណ៍បញ្ជូនទៅការិយាល័យបច្ចេកទេស និងត្រួតពិនិត្យ ដើម្បីអនុវត្ត

៣-ការត្រួតពិនិត្យសំណុំឯកសារពាក្យស្នើសុំលិខិតបិទការដ្ឋាន

-ចុះត្រួតពិនិត្យ ផ្ទៀងផ្ទាត់សំណង់ដែលបានសាងសង់ហើយជាមួយប្លង់អនុញ្ញាត ផ្តល់មតិ និងចុះហត្ថលេខា

-រៀបចំកំណត់ហេតុស្តីពីការចុះពិនិត្យដល់ការដ្ឋានសាងសង់

-រៀបចំលិខិតបិទការដ្ឋាន បញ្ជូនទៅថ្នាក់ដឹកនាំនាយកដ្ឋានពិនិត្យ

៤-អគ្គនាយករង ធ្វើការពិនិត្យ និងមានមូលវិចារណ៍លើកំណត់បង្ហាញសំណុំរឿង រួចបញ្ជូនទៅឯកឧត្តមអគ្គនាយក

៥-ឯកឧត្តមអគ្គនាយកពិនិត្យ និងមានមូលវិចារណ៍លើកំណត់បង្ហាញសំណុំរឿង បញ្ជូនទៅឯកឧត្តមអនុរដ្ឋលេខាធិការ

៦-ឯកឧត្តមអនុរដ្ឋលេខាធិការពិនិត្យ និងមានមូលវិចារណ៍លើកំណត់បង្ហាញសំណុំរឿង រួចបញ្ជូនទៅឯកឧត្តមអគ្គនាយក ដើម្បីចុះហត្ថលេខាលើលិខិតបិទការដ្ឋាន

៧-វាយត្រាចេញ និងចុះលេខចេញ

-បញ្ជូនទៅម្ចាស់សំណើ។

៧

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អគ្គនាយកដ្ឋានសំណង់

នាយកដ្ឋានសំណង់

សន្លឹក៣

## រយៈពេលនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ ដែលជាសមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង

| ល.រ | សមត្ថកិច្ច | ចំនួនថ្ងៃ | ថ្ងៃធ្វើការ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១ | ការិយាល័យរដ្ឋបាល | ០.៥ | ■ | | | | | |
| ២ | អនុប្រធានមន្ទីរទទួលបន្ទុករដ្ឋបាល | ០.៥ | ■ | | | | | |
| ៣ | ការិយាល័យសំណង់ ឬការិយាល័យ ដ.ន | ៣ | | ■ | ■ | ■ | | |
| ៤ | អនុប្រធានមន្ទីរទទួលបន្ទុកសំណង់ | ០.៥ | | | | | ■ | |
| ៥ | ប្រធានមន្ទីរ | ១ | | | | | ■ | ■ |
| ៦ | ការិយាល័យរដ្ឋបាល | ០.៥ | | | | | | ■ |
| | រយៈពេលសរុប | ៦ | | | | | | |

**កំណត់សំគាល់អំពីប្រភេទការងារសំខាន់ៗតាមសមត្ថកិច្ចនីមួយៗ**

១-ពិនិត្យលក្ខណៈគ្រប់គ្រាន់ និងភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យ (Check List)
- -ចុះលេខចូល និងបោះត្រាចូល
- -ចុះបញ្ជីលេខាបង្រួម
- -ចេញបង្កាន់ដៃ (បើឯកសារគ្រប់គ្រាន់)
- -បញ្ជូនសំណុំឯកសារទៅអនុប្រធានមន្ទីរទទួលបន្ទុកការងាររដ្ឋបាល

២-ការពិនិត្យសំណុំឯកសារ
- -ចំណារបញ្ជូនទៅអនុប្រធានមន្ទីរទទួលបន្ទុកការងារសំណង់ ឬទទួលបន្ទុកការងារ ដ.ន

៣-ការពិនិត្យសំណុំឯកសារ និងបំពេញបែបបទបើកការដ្ឋាន
- -ពិនិត្យប្លង់គ្រឿងផ្គុំសំណង់
- -ចុះបោះបង្គោលដោយសហការជាមួយការិយាល័យ ដ.ន.ស.ភ ស្រុក ខណ្ឌ
- -រៀបចំលិខិតបើកការដ្ឋានសាងសង់
- -រូបថតជាក់ស្តែងនៅការដ្ឋានសាងសង់

៤-ការពិនិត្យសំណុំឯកសារស្នើសុំបើកការដ្ឋានសាងសង់
- -ពិនិត្យលើលិខិតស្នើសុំបើកការដ្ឋានសាងសង់
- -ចុះហត្ថលេខាបង្រួមលើលិខិតបើកការដ្ឋាន

៥-ការពិនិត្យសំណុំឯកសារបើកការដ្ឋានសាងសង់
- -ចុះហត្ថលេខាលើលិខិតបើកការដ្ឋានសាងសង់

៦-វាយត្រាចេញ និងចុះលេខចេញ
- -បញ្ជូនទៅម្ចាស់សំណើ

៤

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — សន្លឹក៤

អគ្គនាយកដ្ឋានសំណង់

នាយកដ្ឋានសំណង់

## រយៈពេលនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតបិទការដ្ឋានសាងសង់
## ដែលជាសមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង

| ល.រ | សមត្ថកិច្ច | ចំនួនថ្ងៃ | ថ្ងៃធ្វើការ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១ | ការិយាល័យរដ្ឋបាល | 0.៥ | ■ (ពាក់កណ្តាលទី១) | | | | | |
| ២ | អនុប្រធានមន្ទីរទទួលបន្ទុករដ្ឋបាល | 0.៥ | ■ (ពាក់កណ្តាលទី២) | | | | | |
| ៣ | ការិយាល័យសំណង់ ឬការិយាល័យ ដ.ន | ៣ | | ■ | ■ | ■ | | |
| ៤ | អនុប្រធានមន្ទីរទទួលបន្ទុក ដ.ន ឬ ដ.ន និងសំណង់ | 0.៥ | | | | | ■ (ពាក់កណ្តាលទី១) | |
| ៥ | ប្រធានមន្ទីរពិនិត្យនិងសំរេច | ១ | | | | | ■ (ពាក់កណ្តាលទី២) | ■ (ពាក់កណ្តាលទី១) |
| ៦ | ការិយាល័យរដ្ឋបាល | 0.៥ | | | | | | ■ (ពាក់កណ្តាលទី២) |
| | រយៈពេលសរុប | ៦ | | | | | | |

**កំណត់សំគាល់អំពីប្រភេទការងារសំខាន់ៗតាមសមត្ថកិច្ចនីមួយៗ**

១-ពិនិត្យលក្ខណៈគ្រប់គ្រាន់ និងភាពត្រឹមត្រូវតាមតារាង ក្រួតពិនិត្យ (Check List)
-ចុះលេខចូល និងបោះត្រាចូល
-ចុះហត្ថលេខាបង្រួម
-ចេញបង្កាន់ដៃ (បើឯកសារគ្រប់គ្រាន់)
-បញ្ជូនសំណុំឯកសារទៅអនុប្រធានមន្ទីរទទួលបន្ទុករដ្ឋបាល

២-ការពិនិត្យសំណុំឯកសាររួចធ្វើចំណារបញ្ជូនទៅអនុប្រធានមន្ទីរទទួលបន្ទុក ការងាររៀបចំដែនដី និងនគរូបនីយកម្ម ឬ ការងារសំណង់

៣-ការិយាល័យសំណង់ ឬ ដ.ន ពិនិត្យសំណុំឯកសារ
-ចុះធ្វើសំរង់សំណង់ជាក់ស្តែងលើទីតាំង
-គូសប្លង់ស្ថាបត្យកម្មថ្មីឡើងវិញ
-ផ្តល់មតិនិងចុះហត្ថលេខា
-រៀបចំលិខិតបិទការដ្ឋាន
-បញ្ជូនទៅអនុប្រធានមន្ទីរ ដ.ន ឬ ដ.ន និងសំណង់

៤-អនុប្រធានមន្ទីរទទួលបន្ទុកការងារ ដ.ន ឬ ការងារសំណង់ ចុះហត្ថលេខាបង្រួមលើលិខិតបិទការដ្ឋាន រួចបញ្ជូនទៅប្រធានមន្ទីរ

៥-ប្រធានមន្ទីរពិនិត្យ និងចុះហត្ថលេខាសំរេច
-បញ្ជូនទៅការិយាល័យរដ្ឋបាល

៦-វាយត្រាចេញ និងចុះលេខចេញ
-បញ្ជូនទៅម្ចាស់សំណើ